ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៩៣/០៩ — ណាហ្គាវើលដ៏**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

**ភាគីនៃវិវាទ**

១- ភាគីនិយោជក

ឈ្មោះ : **សាខាក្រុមហ៊ុន ណាហ្គាវើលដ៏ លីមីធីត**

អាសយដ្ឋាន : សួនច្បារសម្តេច ហ៊ុន សែន ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១៥ ៨៨១ ១៩៤ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ហៅ ជីវអេង មេធាវីតំណាងក្រុមហ៊ុន

២- លោក ជា សុខចាន់ ជំនួយការមេធាវី

២- ភាគីកម្មករនិយោជិត

**ឈ្មោះ : សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ និងសេវាកម្មកម្ពុជា**

**សហជីពទ្រទ្រង់សិទ្ធិការងារ បុគ្គលិកកម្មករខ្មែរ នៃមណ្ឌលកំសាន្តណាហ្គា**

អាសយដ្ឋាន : ផ្ទះលេខ ៦ បេ ផ្លូវ២៦៨ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

លេខទូរស័ព្ទ : ០១២ ៩២៧ ២៨៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក សុខ ណារិទ្ធ អនុប្រធានសហព័ន្ធសហជីព CTSWF

២- លោក ដាំ សុផាត ប្រធានគណៈកម្មការវិវាទសហព័ន្ធសហជីព CTSWF

៣- លោក នូ ចាន់ឌី គណៈកម្មការអចិន្ត្រៃយ៍សហព័ន្ធសហជីព CTSWF

៤- កញ្ញា សុផាន់ ដារ៉ា ប្រធានគណៈកម្មការស្ត្រី ណោហ្គាវើលដ៏

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- សហជីពទ្រទ្រង់សិទ្ធិកម្មករខ្មែរមណ្ឌលកំសាន្ត ណោហ្គាវើលដ៏ ស្នើសុំឱ្យក្រុមហ៊ុនបន្តការកាត់ប្រាក់ភាគទានជូនសហជីព ព្រោះកន្លងមក ក្រុមហ៊ុនបានអនុវត្តការកាត់ប្រាក់ភាគទាននេះ តាំងពីឆ្នាំ២០០៦ មកម៉្លេះ។ ម្យ៉ាងទៀត សព្វថ្ងៃនេះ បុគ្គលិកដែលជាសមាជិកសហជីពបានស្ម័គ្រចិត្ត និងយល់ព្រមផ្តិតមេដៃជូនសហជីព ដើម្បីឱ្យក្រុមហ៊ុនបន្តកាត់ប្រាក់ភាគទាន។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចកាត់ប្រាក់ភាគទានជូនសហជីពបានទេ ព្រោះសព្វថ្ងៃបានប្តូរប្រព័ន្ធបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រថ្មី ដែលមិនអាចធ្វើកិច្ចការនេះបានទៀតឡើយ ម្យ៉ាងវិញទៀត យោងតាមមាត្រា ២៨១ នៃច្បាប់ស្តីពីការងារ តាមខ្លឹមសារនេះ ក្រុមហ៊ុនមិនអាចកាត់ប្រាក់ភាគទានជូនសហជីព តាមការស្នើសុំបានឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជាទីងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៩៧៤ ក.ប/អក/វ.ក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩។

**សវនាការ និង សន្ទេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ( វេលាម៉ោង ១៤:០០ នាទី រសៀល ) ។

**បញ្ហានីតិវិធី :**

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងរបស់សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃមណ្ឌលកំសាន្ត ណេហ្គា ស្តីពីការទាមទារឱ្យក្រុមហ៊ុន បន្តកាត់ភាគទានជូនសហជីព ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ លើការទាមទារទាំងអស់ចំនួន ០១ ចំណុច ។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និង ភាគីកម្មករនិយោជិតមកសវនាការ និង ធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ( វេលាម៉ោង ១៤:០០ នាទី ) ។ ភាគីទាំងពីរមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចវិវាទចំនួន ០១ចំណុចនេះ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេលើការទាមទារ ០១ ចំណុចនេះ ។ ដូច្នេះ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើការទាមទារ ០១ ចំណុចនេះ ដោយផ្អែកលើភស្តុតាង និង ហេតុផលដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី :** គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតតំណាងដោយអាណត្តិ របស់មេធាវី ហេ ជីវអេង ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ។

២- លិខិតប្រគល់សិទ្ធិជូនមេធាវី ហេ ជីវអេង តំណាងដោយអាណត្តិ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ។

៣- សារណាសង្ខេបនៃវិវាទ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ។

៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ណេហ្គាវើលដ៍ លីមីធីត ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៨ ។

៥- អនុស្សរណៈ និងលក្ខន្តិកៈ របស់ក្រុមហ៊ុន ណោហ្គាវើលដ៏ លីមីធីត ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៨២។

៦- វិញ្ញាបនប័ត្របញ្ជាក់ចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម សាខាក្រុមហ៊ុន ណាហ្គាវើលដ៏ លីមីធីត លេខ ៣០៧៥ ពណ.ចបព ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨។

៧- លិខិតរបស់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជម្រាបទៅនាយកសាខាក្រុមហ៊ុន ណាហ្គាវើលដ៏ លីមីធីត ស្តីពីករណីប្តូរសមាសភាពនាយកសាខាក្រុមហ៊ុន លេខ ៣៩៧៥ ពណ.ចបព ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨។

៨- សារណាសង្ខេបនៃវិវាទ។

៩- សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៤៧/០៩-ណោហ្គាវើលដ៏ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩។

១០- ឯកសារជាភាសាបរទេស: Terms of cessation of service, Final Settlement, Notice of termination of employment, Computation for separation pay, Stritly private & confidential របស់ឈ្មោះ Hang Seth, Kim Leng Borithy, Leuk Phin, Chhoy Sophino, Lim Chhin Hor, Mao John David, Nou Seap, Pex Sovatey, Phen Samphors, Sek Som Orn, Sok Narith,Sophann Dara, Yean Rany, Youk Samith។

១១- លិខិតរបស់មេធាវី គោរពជូន លោកប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្តល់ព័ត៌មានបន្ថែមជុំវិញសំណុំរឿងលេខ ៩៣/០៩ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- សារណាស្តីពីវិវាទនៅក្រុមហ៊ុន ណោហ្គាវើលដ៏ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩។

២- Payment voucher (ឯកសារជាភាសាបរទេស)។

៣- Nettpay hotel as December 2008 (ឯកសារជាភាសាបរទេស)។

៤- លិខិតរបស់សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍សេវាកម្មកម្ពុជា គោរពជូន លោកក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការជូនព័ត៌មាន និងឯកសារបន្ថែម លើសំណុំរឿងលេខ ៤៣/០៩-សកទ-សក ស្តីពីការបោះបង់ការប្រមូលភាគទានឱ្យសហជីព ដោយកាត់តាមតណនេយ្យរបស់សមាជិកនៅក្រុមហ៊ុន ណោហ្គាវើលដ៏ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩។

៥- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីព ទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃមណ្ឌលកំសាន្ត ណោហ្គា ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០។

៦- លក្ខន្តិកៈសហជីព ទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ លេខ ៩៩ សកបយ.អក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០។

៧- ពាក្យសុំចូលជាសមាជិកសហជីព ទ្រទ្រង់សិទ្ធិការងារ បុគ្គលិកកម្មករខ្មែរ ។

៨- ឈ្មោះបុគ្គលិកគាំទ្រក្នុងការទាមទារឱ្យថ្នាក់ដឹកនាំសហជីព ប្រតិភូបុគ្គលិក និងសកម្មជនត្រឡប់ចូលធ្វើការក្នុងក្រុមហ៊ុនវិញ ចំនួន ៤២ សន្លឹក ។

៩- លិខិតរបស់សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍សេវាកម្មកម្ពុជា គោរពជូន លោកប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការសូមបំភ្លឺព័ត៌មានបន្ថែមរបស់មេធាវីតំណាងឱ្យក្រុមហ៊ុន ណេហ្គាវើលដ៍ លេខ ៤៧/០៩ ស.ក.ទ.ស.ក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណេហ្គាវើលដ៍ លេខ ៥៧៤ ក.ប/អក/វ.ក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ណេហ្គា វើលដ៍ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០០៩ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៤៥៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៤៦០ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ណេហ្គាវើលដ៍ មានជួលកម្មករនិយោជិតសរុបប្រហែល ៣១០០ នាក់ ។
- សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃមណ្ឌលកំសាន្ត ណេហ្គា ដែលជាដើមបណ្តឹងក្នុងរឿងនេះបានបង្កើតឡើងនៅឆ្នាំ ២០០០ ហើយមានសមាជិកប្រហែល ៩៥០ នាក់ ។ សហជីពនេះគ្មានភាពជាតំណាងបំផុតទេ ។

- តាមការអះអាងរបស់ភាគីនិយោជក និង កម្មករនិយោជិត បញ្ជាក់ថា ក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួលកម្មករនិយោជិតចំនួន ២០០០ រៀល ក្នុងមួយខែ ដើម្បីបង់ភាគទានជូនសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃមណ្ឌលកំសាន្ត ណាហ្គា ចាប់តាំងពីសហជីពនៅចុងឆ្នាំ ២០០៦ ហើយក្រុមហ៊ុនទើបតែបញ្ឈប់ការកាត់ប្រាក់ភាគទាន នៅខែមីនា ឆ្នាំ២០០៩។
- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបន្តកាត់ប្រាក់ភាគទានឱ្យសហជីព ដោយយោងតាមមាត្រា ១២៩ នៃច្បាប់ស្តីពីការងារ និង ប្រការ ០៥ នៃប្រកាសលេខ ៣០៥។ ភាគីនិយោជកបញ្ជាក់ថា មិនអាចបន្តកាត់បានទេ ហើយមូលហេតុដែលក្រុមហ៊ុនបញ្ឈប់ការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីបង់ភាគទានសហជីពព្រោះ (១)សហជីពចេះតែដើរប្តឹងក្រុមហ៊ុន. (២) ក្រុមហ៊ុនគ្មានពេលវេលាគ្រប់គ្រាន់នៅពេលក្រុមហ៊ុនបានផ្លាស់ប្តូរកម្មវិធីគ្រប់គ្រងបៀវត្សតាមប្រព័ន្ធកំព្យូទ័រថ្មី. និង (៣) បន្ថែមពីនេះទៀត មាត្រា ២៨១ នៃច្បាប់ស្តីពីការងារហាមឃាត់មិនឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទាន។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ចាប់តាំងពីខែមីនា ឆ្នាំ២០០៩ មក សហជីពមិនបានប្រមូលភាគទានសហជីពពីកម្មករផ្ទាល់ទេ ដោយរង់ចាំការដោះស្រាយជាមួយនឹងក្រុមហ៊ុន។ ប៉ុន្តែរហូតដល់ខែមេសា ក្រុមហ៊ុននៅតែមិនកាត់ប្រាក់ឈ្នួលកម្មករដែលជាសមាជិកសម្រាប់ភាគទានសហជីពទៀត។ នៅខែឧសភា ឆ្នាំ២០០៩ សហជីពបានប្រមូលភាគទានផ្ទាល់ពីសមាជិកបានប្រហែល ៩៩០ នាក់។ សមាជិកទាំងអស់បានស្នើឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលបង់ភាគទានសហជីព ព្រោះពួកគេមានការពិបាកក្នុងការបង់ភាគទាននេះ ហើយការស្នើនេះធ្វើឡើងក្នុងកិច្ចប្រជុំជាមួយសហជីពកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ និង ថ្ងៃទី១២-១៦ ខែមិថុនា ឆ្នាំ២០០៩។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតមិនបានដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទេ។ ហើយសហជីពក៏មិនទាន់បានដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុនដែរ គឺធ្វើតាមបណ្តឹងនេះ ប៉ុន្តែមានការជួបពិភាក្សាជាមួយលោក ហៃ វល្លៀប នាយកផ្នែកល្បែងអំពីបញ្ហានេះ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យភាគីកម្មករនិយោជិត និង ភាគីក្រុមហ៊ុន ផ្តល់ឯកសារពាក់ព័ន្ធនឹងការស្នើសុំកាត់ប្រាក់ភាគទានសហជីពដែលមានកន្លងមក (ឆ្នាំ ២០០៦) និង ឯកសារពាក់ព័ន្ធនឹងការស្នើសុំកាត់ប្រាក់ភាគទានសហជីពដែលរៀបចំថ្មីត្រឹមថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩។ ភាគីកម្មករ-និយោជិតមិនបានផ្តល់ឯកសារពាក់ព័ន្ធនឹងការស្នើសុំកាត់ប្រាក់ភាគទានសហជីពដែលមានកន្លងមក (ឆ្នាំ ២០០៦) និង ឯកសារពាក់ព័ន្ធនឹងការស្នើសុំកាត់ប្រាក់ភាគទានសហជីពដែលរៀបចំថ្មី តាមកាល កំណត់ទេ។
- ភាគីក្រុមហ៊ុនផ្តល់ឯកសារមួយសន្លឹកដោយបញ្ជាក់ថា ក្រុមហ៊ុនគ្មានឯកសារបន្ថែមដើម្បីដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ហេតុផលនៃសេចក្តីសម្រេចៈ

ផ្អែកតាមអង្គហេតុខាងលើ ភាគីនិយោជក និងកម្មករនិយោជិតបញ្ជាក់ថា ក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួលកម្មករនិយោជិតចំនួន ២០០០ រៀល ក្នុងមួយខែ ដើម្បីបង់ភាគទាន ជូនសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃមណ្ឌលកំសាន្ត ណាហ្គា ចាប់តាំងពីចុងឆ្នាំ២០០៦ ហើយក្រុមហ៊ុនទើបតែបញ្ឈប់ការកាត់ប្រាក់ភាគទានទៅខែមីនា ឆ្នាំ២០០៩។

ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបន្តកាត់ភាគទានសហជីពទៀត តែក្រុមហ៊ុនបដិសេធ។ ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោមៈ

កថាខណ្ឌ ២ នៃមាត្រា ១២៩ ច្បាប់ស្តីពីការងារចែងថា *"ប៉ុន្តែកម្មករនិយោជិតអាចអនុញ្ញាតអោយកាត់ប្រាក់ឈ្នួលរបស់ខ្លួនដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក។ ការអនុញ្ញាតនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និង អាចបដិសេធវិញបានគ្រប់ពេលវេលា។"*

ប្រការ ៥ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចែងថា *"កម្មករនិយោជិតទាំងអស់ ដែលជាសមាជិកសហជីពអាចស្នើសុំជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃមុន ដើម្បីឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួនដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក ហើយនិយោជកត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវតាមសំណើនេះ។"*

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការបកស្រាយមាត្រា ១២៩ នៃច្បាប់ស្តីពីការងារ និងប្រការ ៥ នៃប្រកាស ៣០៥ ថា កម្មករនិយោជិតអាចអនុញ្ញាតឱ្យនិយោជកកាត់ប្រាក់ភាគទានសហជីពពីប្រាក់ឈ្នួលរបស់ពួកគេបាន។ ប៉ុន្តែការអនុញ្ញាតនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរនៅគ្រប់ពេលទាំងអស់។ នៅពេលដែលកម្មករនិយោជិតយល់ព្រមឱ្យនិយោជកកាត់ប្រាក់ភាគទាន និយោជកត្រូវតែកាត់ប្រាក់ភាគទានសហជីព ហើយបញ្ជូនទៅឱ្យសហជីព (សូមមើលសំណុំរឿង*លេខ ០៣/០៣-តុងហ្គា ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៩ ,លេខ ០៥/០៣-ថប វ៉ត្ត ឬកាមិន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១* និងលេខ *១៦/០៥-ញូភាញ៉ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១១*) ។

នៅក្នុងសេចក្តីបង្គាប់លេខ ៦២/០៤-អ៊ីស៊ីន ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា *"ប្រសិនបើសហជីពមានបំណងឱ្យនិយោជកកាត់ប្រាក់ភាគទានសហជីពពីប្រាក់ឈ្នួលរបស់កម្មករ សហជីពត្រូវប្រគល់ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ និងអាចយកជាការបាន ដូចជាបញ្ជីឈ្មោះ ដែលមានហត្ថលេខា ឬស្នាមមេដៃរបស់កម្មករ សាម៉ីនិងលិខិតផ្សេងៗទៀតដែលមានលក្ខណៈរួមគ្នាក្តី ឬមានលក្ខណៈជាបុគ្គលក្តីដែលយល់ព្រម និងអនុញ្ញាតឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួនសំរាប់បង់ភាគទានសហជីព។ នៅពេលទទួលបានឯកសារនេះ និយោជកត្រូវកាត់ប្រាក់ភាគទាននេះ ហើយប្រគល់ឱ្យសហជីពរៀងរាល់ខែ។ ជាបន្ថែមទៀត សហជីពត្រូវជូនដំណឹងជា*

*លាយលក្ខណ៍អក្សរឱ្យនិយោជក  អំពីការផ្លាស់ប្តូរការយល់ព្រមឱ្យនិយោជកកាត់ប្រាក់ភាគទានពីប្រាក់ឈ្នួលរបស់កម្មករ ។* ( សូមមើលបន្ថែមសំណុំរឿងលេខ *៦០/០៥-អេវើប្រ្តីន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ១* ) ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងខាងលើ  គឺនិយោជកមានកាតព្វកិច្ចត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតជាសមាជិកសហជីព ដែលបានផ្តល់លិខិតស្នើសុំជាលាយលក្ខណ៍អក្សរ សម្រាប់បង់ភាគទានសហជីព ឱ្យទៅសហជីពដែលបានស្នើសុំឱ្យកាត់ក្នុងករណីសហជីពបានបំពេញលក្ខខណ្ឌតាមច្បាប់ ។

ចំពោះការលើកឡើងរបស់និយោជក ដែលថា មាត្រា ២៨១ នៃច្បាប់ស្តីពីការងារហាមឃាត់ មិនឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទាននោះ នៅក្នុងសេចក្តីបង្គាប់មុនៗរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយខ្លឹមសារនៃមាត្រា ២៨១ នៃច្បាប់ស្តីពីការងារថា ចែងឡើងក្នុងគោលបំណង ដើម្បីការពារសិទ្ធិកម្មករនិយោជិត និងហាមឃាត់និយោជកធ្វើសកម្មភាពជ្រៀតជ្រែកការងារសហជីព និង ក្នុងការធ្វើឱ្យសហជីពនៅក្រោមឥទ្ធិពលរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២៨០ នៃច្បាប់ស្តីពីការងារ ។ (សូមមើលសេចក្តីបង្គាប់លេខ *០៥/០៣-ថប វ័ន្ត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ លេខ ៦២/០៤-អ៊ី ស៊ុន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៩ លេខ ៩៤/០៤- អ៊ីធីនីធី អីកែរីល ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤ លេខ ១៦/០៥-ញូភាញ់ វើលគ្រេត ខេមបូឌា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១១ និងលេខ ៩៩/០៦-សោធ៍ ធាយ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៥ ។)*

ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា  ច្បាប់ស្តីពីការងារមិនហាមឃាត់និយោជកក្នុងការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីបង់ភាគទានសហជីពទេ ក្នុងករណីដែលកម្មករនិយោជិតផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរឱ្យនិយោជកធ្វើដូច្នេះ ។  ក្នុងករណីនេះ  និយោជកមានកាតព្វកិច្ចកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព ។

មួយវិញទៀត មូលហេតុដែលនិយោជកលើកឡើងពីការមិនបន្តនូវការកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានសហជីព ដោយសារ សហជីពចេះតែដើរប្តឹងក្រុមហ៊ុន មិនមែនជាហេតុផលផ្លូវច្បាប់ក្នុងសម្រេចមិនបន្តកាត់ប្រាក់ឈ្នួលនោះទេ ។

ចំពោះការអនុវត្តកន្លងមក  ក្នុងការកាត់ប្រាក់ភាគទានហសជីពតាំងពីឆ្នាំ២០០៦ មកនោះ ភាគីកម្មករនិយោជិតមិនបានដាក់ភស្តុតាង  ដែលបង្ហាញពីភាពច្បាស់លាស់ថា  តើជាការកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីព គោរពតាមច្បាប់ការងារ មាត្រា ១២៩ នៃច្បាប់ស្តីពីការងារ និង ប្រការ ៥ នៃប្រកាស ៣០៥ ដែលបញ្ជាក់ថា  កម្មករនិយោជិតបានអនុញ្ញាតជាលាយលក្ខអក្សរឱ្យនិយោជកកាត់ប្រាក់ភាគទានសហជីពពីប្រាក់ឈ្នួលរបស់ពួកគេនោះទេ ។

ម្យ៉ាងវិញទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា កម្មករនិយោជិតមិនទាន់បាន រៀបចំឯកសារគ្រប់គ្រាន់ ដូចជាពាក្យស្នើសុំជាលាយលក្ខណ៍អក្សររបស់កម្មករនិយោជិត ជាដើម។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃមណ្ឌលកំសាន្ត ណាហ្គា មិនបានបំពេញបែបបទតាមផ្លូវច្បាប់ ក្នុងការស្នើសុំកាត់ប្រាក់ឈ្នួល ដើម្បីបង់ប្រាក់ភាគទានសហជីពទេ។

បន្ថែមពីលើនេះទៀត សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃមណ្ឌលកំសាន្ត ណាហ្គា ក៏មិនបាន ផ្ដល់ឯកសារទាក់ទងនឹងបញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានសហជីព ហើយក៏ មិនបានផ្ដល់នូវពាក្យសុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលដើម្បីភាគទានសហជីព និងលិខិតស្នើសុំជាលាយលក្ខណ៍អក្សរ របស់សមាជិកសហជីពម្នាក់ៗឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានសហជីពនោះ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ។

សរុបសេចក្ដីមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបដិសេធការទាមទាររបស់សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិក កម្មករខ្មែរនៃមណ្ឌលកំសាន្ត ណាហ្គា ឱ្យក្រុមហ៊ុនបន្តការអនុវត្តកាត់ប្រាក់ឈ្នួលចំនួន ២០០០ រៀល ដើម្បីបង់ភាគ ទានសហជីព។ ប៉ុន្តែភាគីនិយោជកមានកាតព្វកិច្ចកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានជូនសហជីពទ្រទ្រង់សិទ្ធិការ ងារបុគ្គលិកកម្មករ ខ្មែរនៃមណ្ឌលកំសាន្ត ណាហ្គា នៅពេលណាដែលសហជីពនេះបានបំពេញបែបបទ តាមមាត្រា ១២៩ កថាខណ្ឌទី២ នៃច្បាប់ការងារ និង ប្រការ៥ នៃប្រកាសលេខ ៣០៥ ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សា អាជ្ញាកណ្ដាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

- បដិសេធការទាមទាររបស់សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃមណ្ឌលកំសាន្ត ណាហ្គា ឱ្យ ក្រុមហ៊ុនបន្តការអនុវត្តកាត់ប្រាក់ភាគទានចំនួន ២០០០ រៀល ដើម្បីបង់ភាគទានសហជីព ។
- បង្គាប់ឱ្យក្រុមហ៊ុនបំពេញកាតព្វកិច្ច កាត់ភាគទានសហជីពពីប្រាក់ឈ្នួលកម្មករនិយោជិតដែលជាសមាជិក សហជីពជូនសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃមណ្ឌលកំសាន្ត ណាហ្គា នៅពេលណាដែល សហជីពនេះបានបំពេញបែបបទ តាមមាត្រា ១២៩ កថាខណ្ឌទី២ នៃច្បាប់ការងារ និង ប្រការ៥ នៃប្រកាសលេខ ៣០៥ ។

**ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមាន ភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈ លេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុង សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------